www.ekasar.com



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ ១៣៩ ស.ក.ប.យ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
## ការងារក្នុងមណ្ឌលហាប់

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

ប្រការ១.- មណ្ឌលហាប់គឺលំហអាកាសនៅក្នុងធុងធំ ស៊ីទែន អន្លង់ បាតនាវា ប្រឡាយបង្ហូរក្នុងដី បំពង់លូ អណ្តូង ផ្លូវក្នុងអណ្តូងរ៉ែ បន្ទប់ក្រោមដី ផលាកជ ។ល។ ដែលមានមាត់រន្ធ ឬច្រកចូលតូច មិនអាចឱ្យមានការផ្លាស់ប្តូរខ្យល់អាកាសបានគ្រប់គ្រាន់សំរាប់ការដកដង្ហើម ។ មណ្ឌលហាប់អាចខ្វះអុកស៊ីហ្សែន ហើយមាន ឬអាចនិងមាន សារធាតុពុល ឬសារធាតុងាយឆាបឆេះ ។ មាត់រន្ធ ឬច្រកចូលនៃមណ្ឌលហាប់ ត្រូវឱ្យមានទំហំសមស្រប សំរាប់ឱ្យកម្មករនិយោជិតអាចចូល ឬចេញ ឬត្រូវបានជួយសង្គ្រោះដោយគ្មានការលំបាក ។ល។

www.ekasar.com



ប្រការ២.- មុននឹងអនុញ្ញាតឱ្យកម្មករនិយោជិតម្នាក់ចូលក្នុងមណ្ឌលហាប់ និយោជកត្រូវមានវិធានការចាំបាច់ដើម្បីធានាសុវត្ថិភាពកម្មករនិយោជិត ជាពិសេសការពារ ៖

- កុំឱ្យមានអគ្គីភ័យឬការផ្ទុះ
- កុំឱ្យមានការថប់ដង្ហើមដោយសារខ្វះអុកស៊ីហ្សែន
- កុំឱ្យពុលដោយសារឧស្ម័ន ចំហាយ ឬធូលីមានជាតិពុល
- កុំឱ្យបរិយាកាសឡើងកំដៅហួសកំណត់
- កុំឱ្យមានការធ្លាក់ពីទីខ្ពស់ ។

ប្រការ៣.- នៅក្នុងការដ្ឋានមណ្ឌលហាប់ ការបក់បញ្ចេញបញ្ចូលខ្យល់ដោយធម្មជាតិ ឬដោយសិប្បនិម្មិតត្រូវមានលទ្ធភាពបក់បញ្ចូលខ្យល់ថ្មីយ៉ាងតិច ៣០ម៉ែត្រគ្រីគុណសំរាប់មនុស្សម្នាក់ក្នុង១ម៉ោង និងពេញរយៈពេលនៃការអនុវត្តន៍ការងារ ។

ប្រការ៤.- ការសាយភាយសារធាតុមានគ្រោះថ្នាក់ដោយសារការអនុវត្តន៍ការងារក្នុងមណ្ឌលហាប់ ដូចជាការផ្សារ ការលាបថ្នាំ ត្រូវបានបឺតចេញតាំងពីដើមប្រភពជាបណ្តើរៗ ឱ្យស្របតាមប្រកាស ស្តីពី *ការបញ្ចេញបញ្ចូលខ្យល់និងការសំអាតបរិយាកាស* ។ បរិមាណខ្យល់ដែលត្រូវបក់បញ្ចូល ត្រូវគិតឱ្យបានសមស្របទៅនិងខ្យល់ដែលបានបឺតចេញ ។ គុណភាពខ្យល់ក្នុងមណ្ឌលហាប់ ត្រូវបានត្រួតពិនិត្យជាទៀងទាត់ពេញរយៈពេលអនុវត្តការងារ ។

ប្រការ៥.- ប្រសិនបើបរិយាកាសនៃមណ្ឌលហាប់មិនអាចសំអាតបានត្រឹមត្រូវទេ កម្មករនិយោជិតដែលបំពេញការងារនៅទីនោះ ត្រូវពាក់ម៉ាស់ការពារមានស្វ័យភាពដែលមិនប្រើខ្យល់ក្នុងមណ្ឌលហាប់សំរាប់ការដកដង្ហើម ។

ប្រការ៦.- នៅក្នុងមណ្ឌលហាប់ និយោជកត្រូវផ្តល់សំភារៈការពារបុគ្គលចាំបាច់មួយចំនួនដូចជា ៖ មួកកាស់ការពារក្បាលនិងមុខ សំលៀកបំពាក់ ស្បែកជើងក្រាស់ ស្រោមដៃ វ៉ែនតា ជាដើម ។

ប្រការ៧.- ប្រសិនបើមណ្ឌលហាប់ជាកន្លែងតូចចង្អៀតឬងាយឆេះនិងផ្ទុះ សំភារៈអគ្គិសនីទាំងឡាយព្រមទាំងសំភារៈសំរាប់បំភ្លឺដែលប្រើប្រាស់នៅទីនោះ ត្រូវធានាថាមានគុណភាពសមស្របល្អ ។

ប្រការ៨.- កាលណាមានកម្មករនិយោជិតណាម្នាក់ចូលទៅធ្វើការនៅក្នុងមណ្ឌលហាប់ និយោជកត្រូវចាត់តាំងឱ្យមានឆ្មាំចាំឃ្លាំមើលជាប្រចាំ ហើយត្រូវរក្សាទំនាក់ទំនងជាប់ជានិច្ចដោយភ្នែក ឬដោយសំឡេង ។ កម្មករនិយោជិតដែលធ្វើការក្នុងមណ្ឌលហាប់ត្រូវមានខ្សែព្រួយុង សំរាប់ទាញយកចេញក្រៅនៅពេលចាំបាច់ ។

ប្រការ៩.- ឆ្មាំដែលចាំឃ្លាំមើលអ្នកធ្វើការក្នុងមណ្ឌលហាប់ ត្រូវមានសំភារៈជួយសង្គ្រោះគ្រប់គ្រាន់និងត្រូវបានរៀនសូត្រអំពី ៖

- វិន័យការងារក្នុងមណ្ឌលហាប់ ៗ.

www.ekasar.com

00196

- ប្រតិកម្មនិងឥរិយាបថនៅពេលមានអាសន្ន
- បច្ចេកទេសជួយសង្គ្រោះ ។

ប្រការ១០.- កម្មករនិយោជិតម្នាក់ មុននិងត្រូវបានចាត់តាំងឱ្យបំពេញភារៈកិច្ចក្នុងមណ្ឌលហប់ ត្រូវបានរៀនសូត្រអំពីវិធានសន្តិសុខសំខាន់ៗដែលត្រូវគោរព និងត្រូវមានលិខិតបង្គាប់ការឱ្យធ្វើប្រតិបត្តិការក្នុងមណ្ឌលហប់ ចេញឱ្យដោយដំណាងសហគ្រាសពេញសមត្ថភាព ។

លិខិតបង្គាប់ការឱ្យធ្វើប្រតិបត្តិការក្នុងមណ្ឌលហប់ត្រូវមានបញ្ជាក់អំពីៈ

- ប្រតិបត្តិការដែលត្រូវធ្វើ
- ឈ្មោះកម្មករនិយោជិតដែលត្រូវធ្វើប្រតិបត្តិការ
- ឈ្មោះនិងឋានៈអ្នកចេញលិខិតបង្គាប់ការ
- ឈ្មោះនិងឋានៈអ្នកចាំឃ្លាំមើល
- វិធានសន្តិសុខសំខាន់ៗដែលត្រូវគោរព ។

ប្រការ១១.- ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុង ជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ១២.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

រដ្ឋមន្ត្រី

អ៊ិត សំហេង

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- អគ្គនាយកដ្ឋាន ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- គ្រប់មន្ទីរសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
- សមាគមនិយោជក "ដើម្បីអនុវត្ត"
- សហភាពសហជីព "ដើម្បីជ្រាប"
- គ្រប់បណ្តាញវិទ្យុនិងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- កាលប្បវត្តិ និងឯកសារ